https://propertyarea.asia/archives/92442 Go AUG SEP OCT
1 capture 07
7 Sep 2023 2022 2023 2024 About this capture

PROPERTY area






























# ក្រុមហ៊ុនធំមួយវិនិយោគជាង ១២លានដុល្លារ លើអគារ Flatiron by Meridian International Holding

February 10, 2022 0




























**ដោយ:សុជារី**

**ភ្នំពេញ:** កាលពីដើមសប្តាហ៍នេះ ID Investors Hub បានចុះកិច្ចសន្យាវិនិយោគគម្រោងទី១របស់ខ្លួន នៅអគារ Flatiron ជាអគារពាណិជ្ជកម្មលំដាប់ A ស្ថិតនៅក្រោមគម្រោងសាងសង់ Meridian International Holding ក្នុងទំហំវិនិយោគជាង១២លានដុល្លាអាមេរិក។






*ចុចទីនេះដើម្បី Subscribe Telegram Channel «Property Area Asia» សម្រាប់ទទួលបានព័ត៌មានថ្មីៗ*




អគារ Flatiron ជាអគារពាណិជ្ជកម្មលំដាប់ A ដែលមានទីតាំងស្ថិតនៅសង្កាត់ស្រះចក ខណ្ឌដូនពេញ ជាចំណុចកណ្ដាល នៃរាជធានីភ្នំពេញ។

លោក ហោ សេរីវឌ្ឍន៍ ប្រធានក្រុមប្រឹក្សាភិបាល IDI និង IDC បានមានប្រសាសន៍ថា យន្តការថ្មីនេះ ក្លាយជាបណ្ដាញដ៏សំខាន់មួយ ក្នុងការប្រមូលផ្ដុំគម្រោងវិនិយោគរបស់ពាណិជ្ជករ សហគ្រិន និងវិនិយោគិនក្នុង និងក្រៅប្រទេស ដែលមានបំណងចង់ទទួលមូលនិធិវិនិយោគ Investment Fund យកមកសិក្សានិងវិភាគ ប្រកបដោយវិជ្ជាជីវៈខ្ពស់ មុនសម្រេចវិនិយោគ ដើម្បីរក្សាសុវត្ថិភាពថវិកា និងផលចំណេញខ្ពស់។



ក្រោយសិក្សា និងវាយតម្លៃស៊ីជម្រៅគ្រប់ជ្រុងជ្រោយ មុនឈានដល់ការសម្រេចចិត្តវិនិយោគ IDI Hub និង ID Capital PLC បានវាយតម្លៃថា ជាគម្រោងអគារ Flatiron ដែលអាចទទួលប្រាក់ចំណេញខ្ពស់ សម្រាប់វិនិយោគិន ប្រៀបនឹងគម្រោងដែលប្រហាក់ប្រហែលនៅក្នុងតំបន់។

IDI Hub ជាបណ្តុំវិនិយោគនាំមុខគេនៅកម្ពុជាមួយ ដែលបានប្រមូលផ្តុំវិនិយោគិននៅក្នុងប្រទេសដែលមានសក្តានុពល ហើយក៏ជាដៃគូសហការរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិជាតិ និងអន្តរជាតិផ្សេងៗផងដែរ។
IDI & IDC ផ្តោតការវិនិយោគលើវិស័យសំខាន់ៗចំនួន៣ គឺ អចលនៈទ្រព្យ សេវាកម្ម និងកសិកម្ម ដែលជាវិស័យឆ្អឹងខ្នងរបស់កម្ពុជា។

Meridian International Holding គឺជាក្រុមហ៊ុនចុះបញ្ជីនៅកម្ពុជាចាប់ផ្តើមឡើងក្នុងវិស័យកាត់ដេរ ហើយឈានមកអភិវឌ្ឍន៍អចលនទ្រព្យ ។ Flatiron by Meridian គឺជាគម្រោងទី៣របស់ Meridian International Holding នៅកម្ពុជា បន្ទាប់ពីអគារ Casa by Meridian ស្ថិតក្នុងតំបន់កោះពេជ្រ និង Skylar by Meridian៕

Facebook Twitter Pinterest

RELATED ARTICLES | MORE FROM AUTHOR

វិបត្តិអចលនទ្រព្យនៅប្រទេសចិនអាចបង្កការខាតបង់ឥណទានប្រមាណ២៦១ពាន់លានដុល្លារអាមេរិក



មហាយក្សចិន នឹងចាត់វិធានការបន្ថែមទៀតដើម្បីស្រោចស្រង់វិស័យអចលនទ្រព្យដែលកំពុងជាប់ផុងក្នុងវិបត្តិបំណុល



ទីក្រុងហាណូយគ្រោងប្រែក្លាយអាផាតម៉ិនពាណិជ្ជកម្មចំនួន៣២០០យូនីត ទៅជាលំនៅដ្ឋានសង្គមសម្រាប់ប្រជាជនមានចំណូលទាប



គោលនយោបាយផ្តល់ទិដ្ឋាការឥតគិតថ្លៃរបស់រដ្ឋាភិបាលថៃនឹងជំរុញការលក់ខុនដូ



ក្រុមហ៊ុន Strategic Realty Investment កំពុងបោះជំហានទៅមុខយ៉ាងធំជាមួយការព្រមព្រៀងពីអ្នកជំនាញអន្តរជាតិ



ទីក្រុងស៊ិនជិនក្លាយជាទីក្រុងបន្ទាប់ទី២របស់ប្រទេសចិន ដែលប្រកាសបន្ធូរបន្ថយច្បាប់កម្ចីទិញផ្ទះលើកដំបូង

‹ ›

## LEAVE A REPLY

Comment:

Name:*

Email:*

Website:

☐ Save my name, email, and website in this browser for the next time I comment.

Post Comment

© រក្សាសិទ្ធិ

